# សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធអគាររដ្ឋបាលព្រៃឈើ
## (នៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៤)

កាលពីដើមអាណត្តិទី២នៃរាជរដ្ឋាភិបាល ខ្ញុំព្រះករុណា ខ្ញុំបានប្រកាសចាប់ផ្តើមជាឱឡារិកនូវកំណែទម្រង់វិស័យព្រៃឈើដ៏ស៊ីជំរៅមួយប្រកបដោយប្រសិទ្ធិភាព ។ ជាមួយនឹងការខិតខំប្រឹងប្រែងជាប្រចាំ និងដោយឥតងាករេ យើងទទួលបាននូវការវាយតំលៃខ្ពស់ និងការគាំទ្រពីមតិជាតិ និងអន្តរជាតិ ក្នុងនោះក៏មានធនាគារពិភពលោកផងដែរ ចំពោះកិច្ចការកែទម្រង់របស់យើង ជាពិសេសគឺការលុបបំបាត់អំពើអនាធិបតេយ្យព្រៃឈើ និងកំណែទម្រង់ព្រៃសម្បទាន ដែលជាមូលដ្ឋានគ្រឹះឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ យ៉ាងណាក៏ដោយ បច្ចុប្បន្នសកម្មភាព កាប់ រាន ដុតព្រៃឈើយកដីព្រៃធម្មជាតិ និងចំការព្រៃ ដំណាំរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិ បាននឹងបន្តកើតឡើងជាបន្តបន្ទាប់នៅតាមបណ្តាខេត្តក្រុងមួយចំនួនដែលជាទង្វើប្រព្រឹត្តិផ្ទុយនឹងច្បាប់ ផ្ទុយនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និង ជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរមួយដែលអាចនាំទៅរកគ្រោះមហន្តរាយនៃវិនាសកម្មព្រៃឈើ និងការខូចខាត បរិស្ថានជីវសាស្ត្ររបស់ជាតិ ។ រាជរដ្ឋាភិបាល មិនអាចព្រងើយកន្តើយ និងអត់អោនចំពោះការបំផ្លិចបំផ្លាញទាំងអស់នេះ បាន ឡើយ ។ ដូច្នេះឆ្លៀតឱកាសនេះ ខ្ញុំករុណាខ្ញុំ សូមប្រកាសបើកឡើងនូវយុទ្ធនាការរួមគ្នាប្រឆាំងនឹងការកាប់ ដុតរាន ឈូស ឆាយ និងហ៊ុមពទ្ធ័កាន់កាប់ដីព្រៃឈើដោយខុសច្បាប់ ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមប្រកាសដាក់បទបញ្ជាអោយគ្រប់ក្រសួង-ស្ថាប័នពាក់ពន្ធ័ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវចូលរួមសហការយ៉ាងជិតស្និទ្ធ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ព្រមទាំងក្រសួងបរិស្ថាន ដើម្បីបង្ក្រាប និងលុបបំបាត់អោយបានដាច់ខាត និងទាន់ពេលវេលា នូវការកាប់ ដុត រុករានដីព្រៃឈើយកធ្វើជាកម្មសិទ្ធិនៅក្នុងទូទាំងផ្ទៃប្រទេស ។ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមប្រកាសព្រមានជាសាធារណៈ ចំពោះជនទាំងឡាយណាដែលមានការពាក់ពន្ធ័នឹងបញ្ហានេះ ទោះជាអ្នកមានបុណ្យសក្តិ អំណាច ឬទ្រព្យសម្បត្តិយ៉ាងណាក្តី ត្រូវបញ្ឈប់ជាបន្ទាន់នូវទង្វើរំលោភបំពានច្បាប់ទាំងអស់នេះ ហើយប្រគល់ជាបន្ទាន់នូវអតីតដីព្រៃឈើទាំងនោះ មកទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើការស្តារ ដាំដុះដើមឈើឡើងវិញ ។ ប្រសិនបើមិនដូច្នោះទេ ទោះបីនរណាក៏ដោយអោយតែហ៊ានប្រព្រឹត្តិខុសច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាស់ជានឹងត្រូវប្រឈមមុខចំពោះវិធានការដ៏មធ្យត័ និងធ្ងន់ធ្ងរជាក់ជាមិនខាន ។

................................................................................................................................................................................................ ។

ប៉ុន្តែអ្វីជាការកត់សំគាល់ ការលួចកាប់ឈើដោយមធ្យោបាយតូចតាច និង ការដឹកជញ្ជូនឈើនៅតែមាននៅឡើយ ។ គ្រោះថ្នាក់ជាងនេះទៅទៀត ឥឡូវនេះបញ្ហាដណ្តើមដីនៅក្នុងព្រៃឈើដែលកាប់ទន្ទ្រានព្រៃឈើយកធ្វើជាកម្មសិទ្ធិផ្ទាល់របស់បុគ្គលអ្នកមានអំណាច និងកំពុងកើតឡើង រួមជាមួយនឹងប្រជាពលរដ្ឋដែលកំពុងខ្វះដីដែលត្រូវការ ។ ការដែលប្រជា

ជនខ្វះដី គឺយើងអាចតំរែតំរង់ផ្លូវរបស់គាត់ ដើម្បីជំរុញអោយគាត់ទៅកាប់ ឬ រុករាននៅតំបន់ណាដែលជាតំបន់ដីកសិកម្ម តាមការចង្អុលបង្ហាញរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ តាមរយៈអាជ្ញាធរដែនដីចង្អុលបង្ហាញប្រជាជនទាំងនោះទៅរកដីនៅទីកន្លែងដែលអាចកាប់ធ្វើជាដីកសិកម្មបាន ។ ប៉ុន្តែយើងសង្កេតឃើញថា ក្នុងរយៈពេលប្រមាណជាជិតមួយឆ្នាំចុងក្រោយនេះ បាតុភាពចាប់ដី ហើយដែលទាក់ទងនឹងដីព្រៃឈើ ធនធានធម្មជាតិរបស់យើង ក៏បានកើតពីអ្នកមានប្រាក់ និងអ្នកមានអំណាចផងដែរ ដែលនៅថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំចេញបញ្ហានៅក្នុងក្របខណ្ឌទូទាំងប្រទេសទាំងស្ថាបន័ស៊ីវិល ជាពិសេសចំពោះកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវធ្វើជាកំលាំងអន្តរាគមន៍ចាំបាច់ ចំពោះរដ្ឋបាលព្រៃឈើរួមជាមួយក្រសួងនគរូបនីយកម្ម ដែនដី និងសំណង់ ក៏ដូចជាក្រសួងបរិស្ថាន ដើម្បីដកហូតត្រលប់មកវិញនូវដីទាំងឡាយណាដែលកាន់កាប់ដោយខុសច្បាប់ពីសំណាក់អ្នកណាក៏ដោយ ។ រដ្ឋបាលព្រៃឈើ ត្រូវធ្វើដើរតួជានគរបាលយុត្តិធម៌ ដើម្បីប្តឹងជននោះទៅកាន់តុលាការ ហើយអំពាវនាវចំពោះតុលាការគ្រប់លំដាប់ថ្នាក់ មេត្តាចាត់ចែង ដើម្បីការពារទ្រព្យសម្បត្តិជាមរតករបស់ប្រជាជនរាប់ពាន់ឆ្នាំមកហើយ និងសំរាប់រាប់ពាន់ឆ្នាំទៅមុខទៀត ។

.........................................................................

លោកយ៉ាន នៅតែស្តាប់បញ្ហានាយករដ្ឋមន្ត្រីអញ្ចឹង ។ ថ្ងៃនេះ អគ្គបញ្ជាការ នាយឧត្តមសេនីយ៍ **ទៀ បាញ់** មកទាំងអស់ហើយជុំគ្នា ហើយថ្ងៃនេះ កំលាំងប្រដាប់អាវុធទាំងអស់ មេទ័ពមេទីង មកទាំងអស់ ដាក់បទបញ្ជាចេញធ្វើការ ។ <u>**កុំភ្លេចរដ្ឋបាលព្រៃឈើ ធ្វើជានគរបាលយុត្តិធម៌ ប្តឹងទារយកដីវិញ ត្រូវហ៊ានធ្វើហ៊ានទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្ររបស់ជាតិ។ បើយើងនៅស្ងៀមព្រៃឈើទាំងនោះនឹងធ្លាក់ទៅជាកម្មសិទ្ធិរបស់បុគ្គលជាមិនខាន ហើយប្រជាជនខ្វះដីរកដីធ្វើមិនបានទេ**</u>។ ឯយើងចេះតែរេចរឹលព្រៃរហូតដល់ព្រៃចំការដែលយើងបានដាំក្នុងរយៈកាលកន្លងមកនេះក៏ត្រូវបានកាប់។ យើងដាំនៅទសវត្សរ៍ឆ្នាំ ៨០ ក៏ប៉ុន្តែមកកាប់នៅពេលឥឡូវ នេះយើងដាំទសវត្សរ៍៩០ ក៏ប៉ុន្តែមកកាប់ពេលនេះ ។ អញ្ចឹងតើការដាំដុះរបស់យើងបានផលប្រយោជន៍អ្វី បើមួយឆ្នាំៗយើងប្រើប្រាស់ទុនយ៉ាងធំដើម្បីដាំ ក៏ប៉ុន្តែត្រូវបានបំផ្លាញទៅវិញមួយផ្នែកបំផ្លាញដោយធម្មជាតិគឺភ្លើងឆេះព្រៃ ប៉ុន្តែបញ្ហាដែលអាក្រក់បំផុតគឺ បំផ្លាញដោយអ្នកមានអំណាច និងអ្នកមានប្រាក់ ទៅកាប់បំផ្លាញព្រៃឈើ ។

....................................................................................................................................................
.................................. ។

ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះដើម្បីរំលឹកជាថ្មីម្តងទៀតចំពោះគ្រប់ក្រសួង-ស្ថាបន័ទាំងអស់របស់រាជរដ្ឋាភិបាល ពិសេសក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើជាសេនាធិការ សូមបន្តការខិតខំអនុវត្តតួនាទី និង ភារកិច្ចរបស់ខ្លួនអោយបានសមស្របតាមច្បាប់ ដោយជំរុញនិងលើកកំពស់សមត្ថភាពអោយសហគមន៍នៅតាមមូលដ្ឋានចូលរួមកាន់តែសកម្មច្រើនឡើងនៅក្នុងការគ្រប់គ្រងធនធានព្រៃឈើអោយមានប្រសិទ្ធិភាពខ្ពស់ ហើយធានាអោយបាននូវចិរភាព និងនិរន្តរភាពនៃធនធានព្រៃឈើ ព្រមទាំងនូវការផ្តល់វិភាគទានជាអតិបរមារបស់ធនធានព្រៃឈើដល់ការលើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជនបទ ។

ទន្ទឹមនឹងនេះដែរ ដោយសារថារដ្ឋបាលព្រៃឈើ ដែលជាសេនាធិការរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកចូលរួមគ្រប់គ្រងព្រៃឈើសហគមន៍ ជាមួយសហគមន៍មូលដ្ឋានដោយផ្ទាល់នោះ ខ្ញុំព្រះករុណាខ្ញុំសូមអោយស្ថាបន័នេះខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួននៅក្នុងការទទួលខុសត្រូវខ្ពស់ និងមានលក្ខណៈបើកចំហប្រកបដោយតម្លាភាពដោយតម្កល់ឧត្តមប្រយោជន៍រយៈពេលវែងរបស់ជាតិ និងប្រជាជនជាធំ ។ ........................................................។

# សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ឆ្នាំ ២០០៤-២០០៥ និងលើកទិសដៅឆ្នាំ ២០០៥-២០០៦
# (ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៥)

៚៚៚ ❋ ៙៙៙

..............................................................................................................................................
.................។

ជាការពិត អង្គសន្និបាតដែលយើងកំពុងប្រារព្ធធ្វើ គឺជាឱកាសមួយដ៏ប្រពៃសំរាប់យើងទាំងអស់គ្នា ពិចារណាបូកសរុបសមិទ្ធផល និងបទពិសោធន៏ក្នុងឆ្នាំមុន ហើយប្រមើលអោយឃើញនូវបញ្ហាប្រឈមមុខសំរាប់អនាគតនៃការអភិវឌ្ឍន៏វិស័យកសិកម្ម ។

ជាក់ស្តែង សកម្មភាពល្មើសច្បាប់នៅពុំទាន់បានកាត់បន្ថយជាអតិបរមានៅឡើយ ដោយករណីនេះមានលក្ខណៈស្មុគ្រស្មាញពាក់ពន្ធ័ជាមួយក្រុមមនុស្សខុសៗគ្នា ជាពិសេសពាក់ពន្ធ័ជាមួយអ្នកមានអំណាច កំលាំង លុយកាក់ និងប្រជាជនក្រីក្រដែលត្រូវបានគេប្រើប្រាស់ជាកំលាំងជួរមុខក្នុងការកាប់រាន ដុត ឈូសឆាយព្រៃ តាមរយៈការជួលផ្ទាល់ ឬទិញបន្តក្នុងតម្លៃថោក។ ជាថ្មីម្តងទៀត ខ្ញុំសូមប្រកាសព្រមានជាសាធារណៈចំពោះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោកលោកស្រីទាំងឡាយណាដែលមានការពាក់ពន្ធ័នឹងបញ្ហានេះ ត្រូវដកខ្លួនជាបន្ទាន់ដោយប្រគល់អតីតដីព្រៃឈើទាំងនោះមកទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើការស្តារដាំដុះដើមឈើឡើងវិញ។ ប្រសិនបើមិនដូច្នោះទេ នឹងត្រូវប្រឈមមុខចំពោះវិបត្តិដ៏ធ្ងន់ធ្ងរជាពុំខាន។ ............... ម៉្យាងទៀត ខ្ញុំនៅតែចាត់ទុកថាការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ដោយផ្សារភ្ជាប់ការធ្វើអាជីវកម្មទៅនឹងការអភិវឌ្ឍន៏ធនធានជលផល និង ព្រៃឈើ ការដាំដុះព្រៃឈើឡើងវិញ ការធ្វើវារីវប្បកម្ម ការការពារបរិស្ថាន គឺជាបញ្ហាដែលមានសារសំខាន់ និងមានតម្លៃបំផុតសំរាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ រុក្ខជាតិ និងជីវៈចំរុះផ្សេងៗទៀតជាច្រើន ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិអោយបានរឹងមាំ។ ............ ខ្ញុំសូមយកឱកាសដ៏មានសារសំខាន់នេះ ដើម្បីលើកនូវទស្សនៈ និងដាក់ចេញនូវអនុសាសន៏មួយចំនួនដល់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួង-ស្ថាប័នពាក់ពន្ធ័ ដូចតទៅ :

ទី១-............................
ទី២-............................
ទី៣-............................
ទី៤-............................
ទី៥-............................
ទី៦-............................

***ទី៧***-ចំពោះបញ្ហាព្រៃឈើ ខ្ញុំបានលើកពីខាងដើមខ្លះរួចមកហើយ ប៉ុន្តែខ្ញុំសូមរំលឹកបន្ថែមទៀតថា ខ្ញុំបានជូនឯកឧត្តម **ចន្ទ័ សារុន** ដឹកនាំរៀបចំបេសកកម្មបង្ក្រាបបទល្មើសព្រៃឈើមួយ កាលពីថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៥ កន្លងមកនេះ កម្លាំងប្រតិបត្តិការចំរុះមួយបានត្រូវបង្កើតឡើង និងដឹកនាំដោយនាយឧត្តមសេនីយ៍ **ជា សារ៉ន** បានចុះបង្ក្រាបបទល្មើសព្រៃឈើក្នុងភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដោយទទួលបានលទ្ធផល និង ជាគជ័យគួរអោយកោតសរសើរនិងសូមស្នើអោយបន្តដឹកនាំ និងរៀបចំបេសកកម្មនេះតទៅទៀតនៅទីកន្លែងណា ដែលមានកើតបទល្មើសខ្លាំងក្លា។ ម៉្យាងទៀត បញ្ហាកាប់រាន ដុតបំផ្លាញ ឈូសឆាយរំលោភយកដីព្រៃឈើធ្វើជាកម្មសិទ្ធិស្ថិតនៅជាបញ្ហាដ៏ក្តៅគគុក

ដែលត្រូវតែមានវិធានការលុបបំបាត់ និងកាត់បន្ថយអោយបានជាអតិបរមា ដែលខ្ញុំសូមដាក់បន្ថែមនូវវិធានការមួយចំនួនដូចតទៅ :

១. មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង ត្រូវបញ្ឈប់ផ្តល់ឯកសារណាដែលពាក់ពន្ធ័ដល់ការផ្តល់បណ្ណ័សំគាល់សិទ្ធិកាន់កាប់ ឬបណ្ណ័កម្មសិទ្ធិលើដីព្រៃដែលផ្ទុយនឹងច្បាប់ស្តីពីព្រៃឈើ ។

២. អាជ្ញាធរដែនដី និងស្ថាប័នពាក់ពន្ធ័ ត្រូវដឹកនាំសហការអនុវត្តបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៤ ដើម្បីប្រយុទ្ធប្រឆាំងការកាន់កាប់រានយកដីព្រៃឈើ រំលោភដីព្រៃឈើធ្វើកម្មសិទ្ធិដោយល្មើសច្បាប់ ។

៣. ចំពោះអ្នកមានអំណាច អ្នកមានប្រាក់កាក់ ត្រូវធ្វើការលះបង់ប្រគល់ដីព្រៃឈើជូនរដ្ឋ ដើម្បីប្រយោជន៍សាធារណៈជាគំរូជូនប្រជាពលរដ្ឋផ្សេងទៀត ដោយអនុវត្តដូចយុទ្ធនាការប្រមូលពន្ធលើយានយន្តគ្រប់ប្រភេទកន្លងមកជាគំរូ ឬ ត្រូវប្រឈមមុខនឹងវិធានការផ្លូវច្បាប់ ។

៤. ក្នុងករណីពិនិត្យ និងស្រាវជ្រាវរកឃើញថាអ្នកប្រព្រឹត្តិខុស មិនសហការចូលរួមដោះស្រាយបញ្ហាទេនោះ ហើយបើមានអ្នករាយការណ៍សំងាត់ណាមួយរកឃើញករណីនេះគឺត្រូវបានលើកទឹកចិត្តនិងរក្សាសិទ្ធិជូន ។ ចំពោះជនល្មើសរំលោភដីព្រៃឈើ នឹងត្រូវប្រកាសដកតួនាទីក្នុងករណីជាមន្ត្រីរាជការរួចបញ្ជូនទៅតុលាការវិនិច្ឆ័យទោសតាមច្បាប់ស្តីពីព្រៃឈើ ។

៥. គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ សូមចូលរួមជំរុញការដាំដើមឈើឡើងវិញលើផ្ទៃដីវិចរិល និងគ្រប់ទីកន្លែងដែលអាចដាំព្រៃឈើបាន ដើម្បីចូលរួមស្តារ និងអភិវឌ្ឍន៏សង្គមជាតិឡើងវិញ ។

✻

**សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឆ្នាំ ២០០៥-២០០៦ និងលើកទិសដៅឆ្នាំ ២០០៦-២០០៧**

**(នៅសាលសន្និសិទចតុមុខ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៦)**

✻

........................................................................................................................................................ ។

ដោយឡែក ការការពារធនធានធម្មជាតិដូចជាព្រៃឈើ ជលផល ដីធ្លីកសិកម្ម អំពើអនាធិបតេយ្យបានកើតឡើងយ៉ាងធ្ងន់ធ្ងរគួរឱ្យគត់សំគាល់ ដូចជាបាត់ភាពអនាធិបតេយ្យកាប់រាន ដុត ឈូសឆាយយកដីព្រៃឈើធ្វើជាកម្មសិទ្ធិតាមគ្រប់រូបភាព ការកាប់ព្រៃលិចទឹក ការដឹកជញ្ជូនឈើ សត្វពាហនៈដោយខុសច្បាប់ គួបផ្សំទៅនឹងភាពរាំងស្ងួតនាពាក់កណ្តាលរដូវ បាតុភាពដឹកស្រូវអង្ករនាំចេញក្រោយពេលប្រមូលផល ការធ្លាក់ចុះតម្លៃកសិផល ។ល។ បានធ្វើឱ្យរាជរដ្ឋាភិបាលមានក្តីកង្វល់ពុំចេះចប់ ។ ...... ដោយឡែក អនុសាសន៍មួយចំនួនដែលខ្ញុំបានដាក់ចុះកាលពីឆ្នាំមុន ខ្ញុំពិនិត្យឃើញថាពុំទាន់បានអនុវត្តគ្រប់ជ្រុងជ្រោយនៅឡើយ ជាពិសេស បញ្ហាកាប់រានដុតឈូសឆាយ យកដីព្រៃឈើធ្វើជាកម្មសិទ្ធិយ៉ាងអនាធិបតេយ្យដែលខ្ញុំបានផ្តល់នូវវិធានការជាច្រើនដើម្បីបំបាត់រូបភាពនេះឱ្យខាងតែបាន ។ ....... ខ្ញុំសូមឆ្លៀតយកឱកាសនេះ

ណែនាំដល់គ្រប់ក្រសួងពាក់ពន្ធ័ទាំងអស់ចាត់តំណាងដែលមានសមត្ថភាព និងសិទ្ធិសម្រេច ជាពិសេសអាជ្ញាធរខេត្ត-ក្រុង គ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម ដើម្បីរួមគ្នាដោះស្រាយរកចម្លើយឱ្យបានសមស្របក្នុងការអនុវត្ត ទិសដៅដែលនឹងគ្រោងទុកសម្រាប់ឆ្នាំខាងមុខដែលខ្ញុំសូមលើកនូវទស្សនៈនិងអនុសាសន៍មួយចំនួនដូចតទៅ :

ទី១-.............................

ទី២-.............................

ទី៣-.............................

ទី៤-.............................

**ទី៥**-រាល់អនុសាសន៍ដែលខ្ញុំបានលើកឡើងកន្លងមកទាក់ទងនឹងវិស័យព្រៃឈើ គ្រប់ស្ថាប័នពាក់ពន្ធ័ត្រូវបន្តអនុវត្ត ឱ្យមានប្រសិទ្ធិភាពខ្ពស់ដោយ ***ពុំត្រូវរកោតញញើត*** និង ***យោគយល់***ឡើយ ។ ទន្ទឹមនឹងនេះ **ត្រូវប្រកាសកំណត់យកផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ធ្វើជាផែនទីគោលសម្រាប់ជាមូលដ្ឋានក្នុងដំណើរការកំណត់ព្រំប្រទល់ដែនព្រៃឈើកម្ពុជា** ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមឱ្យក្រសួងយុត្តិធម៌ ***ប្រកាន់ជំហរតឹងរ៉ឹង*** និង ***ត្រូវជំរុញជាបន្ទាន់*** ទៅតុលាការខេត្ត-ក្រុង ជាពិសេស ណែនាំព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះករណីបទល្មើសកាប់រានដីព្រៃ ។ ទន្ទឹមនឹងនេះដែរ ត្រូវចាត់តាំងឱ្យក្រុមមេធាវីចំណាន៧របស់រាជរដ្ឋាភិបាលចូលរួមការពារក្តីពាក់ពន្ធ័ ជាមួយករណីបទល្មើសកាប់រានដុត ឈូសឆាយ និងហ៊ុមពទ្ធ័ដីព្រៃឈើ ដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិនៅទូទាំងប្រទេស ។

ទី៦-.............................

ទី៧-.............................

.................................................................................................................................... ។

ᢀᢀᢀ ❋ ᢀᢀᢀ

**សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍**
**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងឱកាសសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០០៨**
***"ការគ្រៀងគរធនធានកម្ពុជា មានធនធានមនុស្ស ធនធានធម្មជាតិ ធនធានហិរញ្ញវត្ថុ***
***សំរាប់ការអភិវឌ្ឍន៍ កំណើនសេដ្ឋកិច្ច និង វិបុលភាពប្រកបដោយគុណភាព"***
**(នៅសណ្ឋាគារភ្នំពេញ, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨)**

ᢀᢀᢀ ❋ ᢀᢀᢀ

.......................................................................................................................................... ។

**-កម្មវិធីផ្តល់កម្មសិទ្ធិដីចាំបាច់ត្រូវបន្តធ្វើ បន្ថែមលើជោគជ័យក្នុងការផ្តល់កម្មសិទ្ធិដីចំនួនជាងមួយលានក្បាលដីកន្លង** ។ យើងគួរតែទទួលស្គាល់ពីភាពសាំញ៉ាំនៃប្រវត្តិសាស្ត្រក្នុងការផ្តល់កម្មសិទ្ធិដីធ្លី ។ ច្បាប់ភូមិបាលថ្មីបានផ្តល់ជាក្របខណ្ឌច្បាស់លាស់ដើម្បីផ្តល់កម្មសិទ្ធិដីធ្លី ហើយក្នុងជំហានប្រាំឆ្នាំដំបូង រាជរដ្ឋាភិបាល បានផ្តល់កម្មសិទ្ធិដីចំនួនច្រើន ១លានក្បាលដី ។ បទពិសោធន៍ពីជំហានទីមួយ គួរតែអាចជំរុញដំណើរការនៃការផ្តល់កម្មសិទ្ធិដីលឿនជាងមុន ។ ***ការធ្វើផែនទីដីសាធារណៈរបស់រដ្ឋ និងការកំណត់ព្រំប្រទល់ដីព្រៃ ជាការចាំបាច់ណាស់ក្នុងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ក៏ដូចជាចូលរួមចំណែកក្នុងការកាត់បន្ថយជំលោះផ្សេងៗ*** ។ .................................................................................................. ។

ᢀᢀᢀ ❋ ᢀᢀᢀ

## សម្រង់សុន្ទរកថាគន្លឹះ និងអនុសាសន៍

## សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីសម្ពោធអគារសាលប្រជុំនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងពិធីបិទសន្និបាតបូកសរុប ការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ឆ្នាំ ២០០៨-២០០៩ និងលើកទិសដៅឆ្នាំ ២០០៩-២០១០

## (នៅសាលកលវិទ្យាល័យភូមិនកសិកម្ម, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩)

៙៙៙ ❋ ៙៙៙

ទី១-............................................................................................................................................................ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសេនាទ និងស្ថាប័នពាក់ពន្ធ័ដទៃទៀតត្រូវៈ

១-.............................

២-.............................

៣-............................

៤-ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដែលមានមន្ទីរជំនាញ និងការិយាល័យភូមិបាលស្រុក ក៏ដូចជាក្រសួងមហាផ្ទៃ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ខេត្ត ស្រុក ក្រុង និងជាពិសេស មេឃុំ ចៅសង្កាត់ និងមេភូមិត្រូវបញ្ឈប់ការបញ្ជាក់លីការលក់-ទិញ ឬផ្ទេរកម្មសិទ្ធិដីធ្លីដែលអាចមានការពាក់ពន្ធ័ជាមួយដីព្រៃឈើ ឬដីព្រៃលិចទឹក ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ជាពិសេសនៅទីណាដែលមិនទាន់មានការកំណត់ព្រំប្រទល់ដែនព្រៃឈើជាសម្បត្តិសាធារណៈរបស់រដ្ឋនៅឡើយនោះ គឺមិនត្រូវមានការបញ្ជាក់ទទួលស្គាល់ការទិញ-លក់ និងកម្មសិទ្ធិដីធ្លីទេ ។

៣-............................ ។

### ***ទី២-អំពីវិស័យព្រៃឈើ***

១-ត្រូវពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងព្រៃឈើ ធ្វើយ៉ាងណារក្សានូវគម្របព្រៃឈើឱ្យបាន ៦០%នៃផ្ទៃដីប្រទេសស្របតាមគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាឆ្នាំ ២០១៥ ដោយត្រូវសិក្សាឱ្យបានហ្មត់ចត់ ក្នុងករណីមានសំណើបង្វែរដីព្រៃឈើរបស់រដ្ឋទៅប្រើប្រាស់ផ្សេងក្រៅពីការដាំដុះដើមឈើបង្កើតជាក្រៅពីការដាំដុះដើមឈើបង្កើតជាព្រៃឈើនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវធ្វើការសិក្សាត្រួតពិនិត្យឡើងវិញ និងមានវិធានការហ៊ឹងម៉ាត់ចំពោះក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលមិនគោរពកិច្ចសន្យា ។

២-គ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវចូលរួមសហការជាមួយរដ្ឋបាលព្រៃឈើ ដោយបង្កើនល្បឿនបោះបង្គោលកំណត់ព្រំប្រទល់ដែនព្រៃឈើឱ្យបានឆាប់រហ័សយ៉ាងតិច ១.000គីឡូម៉ែត្រក្នុង១ឆ្នាំ ។ ត្រូវរៀបចំកម្មវិធីព្រៃឈើជាតិសម្រាប់ជួយតម្រង់ទិសដៅនៃដំណើរការគ្រប់គ្រងវិស័យព្រៃឈើ និងធនធានព្រៃឈើកម្ពុជាប្រកបដោយចិរភាព ដោយត្រូវសម្រេចឱ្យបានក្នុងឆ្នាំ ២០០៩នេះ ស្របតាមការកំណត់ក្នុងសូចនាករតាមដានរួមរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ ។

៣-រដ្ឋបាលព្រៃឈើ ត្រូវធ្វើការតាមដាន និងសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅនិងទាន់ពេលវេលាអំពីសភាពការអន្តរជាតិស្តីពីបញ្ហាព្រៃឈើលើពិភពលោក ដូចជា កាលានុវត្តភាពនៃទីផ្សារឥណទានកាបូនព្រៃឈើ ដែលសហគមន៍ពិភពលោកទាំងមូលកំពុងយកចិត្តទុកដាក់ជាមួយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនកំដៅនៃភពផែនដីនោះ ។ យើងត្រូវការពារព្រៃឈើរបស់យើងដោយឈប់ធ្វើអាជីវកម្មកាប់ឈើនាំចេញ មកជាការលក់ខ្យល់បរិសុទ្ធ (ឥណទានកាបូន) វិញដែលកើតឡើងពីព្រៃឈើរបស់យើង ហើយប្រើប្រាស់ចំណូលទាំងនេះមកជួយថែរក្សាព្រៃឈើ និងជួយកាត់បន្ថយភាពក្រីក្រ

របស់ប្រជាជនសហគមន៍មូលដ្ឋាន។ ម្យ៉ាងទៀត ការដាំដុះព្រៃឈើត្រូវតែបន្ត ព្រមទាំងបង្កើនសកម្មភាពឱ្យបានខ្លាំងក្លាថែមទៀត ជាពិសេសត្រូវធ្វើការដាំដុះនៅតំបន់ភ្នំរិចរិល និងទីជម្រាលដែលមានការហូរច្រោះខ្លាំង ដោយបង្កើតជាស្ថានីយ៍ស្តារនិងផ្សព្វផ្សាយព្រៃឈើនៅតំបន់ទាំងនោះ ។

៤-បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ បទបញ្ជា លិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ជាប្រចាំ ដើម្បីទប់ស្កាត់និងលុបបំបាត់អំពើអាណាធិបតេយ្យព្រៃឈើគ្រប់ប្រភេទ។ ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំសុំស្នើដល់ស្ថាប័នអយ្យការ និងតុលាការយកចិត្តទុកដាក់ឱ្យបានឆាប់រហ័សចំពោះសំណុំរឿងបទល្មើសព្រៃឈើនិងផ្តន្ទាទោសជនល្មើសដែលសមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើបានប្តឹងទៅដល់តុលាការ ។

៚ ❋ ៛